# 广 西 民 族 大 学

# 2010年硕士研究生入学考试初试自命题科目试题

（试卷代号：A 卷）

科目代码：____________________

科目名称：基础柬埔寨语

适用学科专业：____________________

研究方向：____________________

命题教师签名：____________________

## 考生须知

1. 答案必须写在答题纸上，写在试题上无效。
2. 答题时一律使用蓝、黑色墨水笔作答，用其它笔答题不给分。
3. 交卷时，请配合监考人员验收，并请监考人员在准考证相应位置签字（作为考生交卷的凭证）。否则，产生的一切后果由考生自负。

一、柬文填空（每空格 1 分，共 30 空格，总分 30 分）

1. ប្រទេសកម្ពុជាមានឈ្មោះផ្លូវការជា ___ រាជធានីគឺក្រុង ___ ភាសាជាតិគឺ___ ក្រៅពីនេះ ភាសា_____ និង _____ក៏ប្រើជាទូទៅបានដែរ។ ឯកតារូបិយប័ណ្ណគឺ ___។

2. សាសនាជាតិនៃប្រទេសកម្ពុជាគឺ___ ដែលចែកជា២និកាយ គឺ____ និង____ ក្រៅពីនេះ ក្នុងកម្ពុជានៅមានសាសនា_____ និងសាសនា_____ជាដើម។

3. ទន្លេ_____មានប្រភពនៅខ្ពស់រាប____ ដែលជាទន្លេធំជាងគេនៅកម្ពុជា មានប្រវែងប្រហែល____ គ.ម. ហើយទន្លេ ____ជាទន្លេធំទី២នៅកម្ពុជា ដែលបានតភ្ជាប់ទន្លេ_____និងបឹង_____ ដែលជាបឹងទឹកសាបធំជាងគេនៅតំបន់_____។

4. កម្ពុជាមានប្រវត្តិសាស្ត្រដ៏យូរលង់ បានបង្កើតជាប្រទេសនៅស.វ.ទី ___ សម័យបុរាណបានឆ្លងកាត់សម័យ_____ _____ និងអង្គរ។ ចាប់ពីចុងស.វ.ទី១៦ទៅស.វ.ទី____ កម្ពុជាបានធ្លាក់ជារដ្ឋចំណុះរបស់សៀម។ នៅឆ្នាំ______ កម្ពុជាបានធ្លាក់ខ្លួនជារដ្ឋ_________របស់ប្រទេសបារាំង។

5. កាលពីថ្ងៃទី ខែ ___ឆ្នាំ___ កម្ពុជាបានទទួលឯករាជ្យ។ ក្រោយការបោះឆ្នោតនាឆ្នាំ១៩៩៣ កម្ពុជាបានក្លាយជារបប_____។ នៅឆ្នាំ____ កម្ពុជាបានចូលជាសមាជិកមួយរបស់សមាគមអាស៊ាន ហើយកាលពីខែកញ្ញា ឆ្នាំ២០០៣ កម្ពុជាបានចូលរួមអង្គការ ___។

二、翻译（第 1 小题 42 分，第 2 小题 28 分，共 70 分）

1.

សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកាលពីព្រឹកថ្ងៃទី១០ ធ្នូ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ត្រឡប់មកពីចូលរួមបើកការប្រកួតកីឡាស៊ីហ្គេមលើកទី២៥ នៅទីក្រុងវៀងច័ន្ទនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត

ឡាវវិញហើយ ។ អញ្ជើញទៅទទួលបដិសណ្ឋារកិច្ចសម្តេចតេជោនិងលោកជំទាវនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញក្នុងឱកាសនោះ រួមមានឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវប្រចាំនៅព្រះរាជា-ណាចក្រកម្ពុជាមន្ត្រីរាជការអ្នកមុខអ្នកការស្ថាប័នរាជរដ្ឋាភិបាលជាច្រើន ។

ដោយឡែកនៅក្នុងសន្និសីទសារព័ត៌មានមួយ លោក អ៊ុង ស៊ាន រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានថ្លែងប្រាប់អ្នកសារព័ត៌មានអំពីលទ្ធផលនៃដំណើរទស្សនកិច្ចបំពេញការងារ និងការអញ្ជើញចូលរួមពិធីបើកការប្រកួតកីឡាស៊ីហ្គេមលើកទី២៥នៅទីក្រុងវៀងច័ន្ទរបស់សម្តេចនាយករដ្ឋមន្ត្រីថា ក្នុងដំណើរបំពេញទស្សនកិច្ចផ្លូវការនោះ សម្តេចតេជោមានគោលបំណងពីរ គឺ ទី១-បំពេញទស្សនកិច្ចកាងារ ទី២-អញ្ជើញចូលរួមបើកការប្រកួតកីឡាស៊ីហ្គេមលើកទី២៥ ។ លោករដ្ឋលេខាធិការបន្តថា ក្នុងអំឡុងពេលបំពេញទស្សនកិច្ចនៅទីក្រុងវៀងច័ន្ទ ក្នុងក្របខណ្ឌនៃការបំពេញទស្សនកិច្ចការងារនោះ សម្តេចតេជោបានជួបពិភាក្សាការងារជាមួយលោកប៊ូសន បុប្ផាវ៉ាន់ នាយករដ្ឋមន្ត្រីឡាវ ។ បន្ទាប់មក សម្តេចក៏បានជួបសំដែងការគួរសមជាមួយលោកប្រធានរដ្ឋជុំម៉ាលី សៃយ៉ាសន ដែលក្នុងកិច្ចពិភាក្សាទ្វេភាគីនោះភាគីទាំងពីរបានផ្តោតទៅលើកិច្ចពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ គឺព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដោយបានរំលឹកឡើងវិញនូវអ្វីដែលបានព្រមព្រៀងគ្នា ពេលដែលលោកនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រ-ជាមានិតឡាវ អញ្ជើញមកធ្វើទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជាកាលពីពេលថ្មីៗកន្លងទៅគឺពង្រឹងកិច្ចសហប្រតិបត្តិការថែមទៀត ក្នុងនោះក៏បានលើកពីចំណុចផ្លាស់ប្តូរនិស្សិត ដើម្បីបន្តការសិក្សានៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងទទួលយកនិស្សិតឡាវមកបន្តការសិក្សានៅព្រះរាជាណាចក្រកម្ពុជារយៈពេលវែងដែរ ។ នៅឆ្នាំ២០១០ ភាគីទាំងពីរបានឯកភាពគ្នាថា

នឹងបង្កើនចំនួននិស្សិត ដែលត្រូវបញ្ជូនទៅសិក្សានៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងទទួលយកនិស្សិតឡាវមកសិក្សានៅកម្ពុជា ដែលពីមុនមានចំនួនតែ៦នាក់នោះគឺត្រូវបន្ថែមឱ្យបាន១០នាក់។ ចំពោះអាហារូបករណ៍ ក៏ត្រូវបន្ថែមផងដែរ ដែលនិស្សិតម្នាក់ៗត្រូវទទួលបន្ថែមចំនួន២០ភាគរយក្នុងមួយខែ ហើយទៅអនាគតនឹងបង្កើនចំនួននិស្សិតបន្ថែមជាបន្តបន្ទាប់ទៅតាមសមត្ថភាពរបស់ប្រទេសនីមួយៗ។ លោកអ៊ុងស៊ាមបានថ្លែងបញ្ជាក់ថា ចាប់ពីឆ្នាំ២០១១ទៅ ប្រទេសនីមួយៗអាចមានលទ្ធភាពបង្កើនចំនួននិស្សិតដោយមិនចាំបាច់កំណត់ទេ អ្នកណាមានលទ្ធភាពច្រើនគឺបញ្ជូនទៅច្រើន ពីព្រោះនៅកម្ពុជាបច្ចុប្បន្ននេះមានសាកលវិទ្យាល័យឯកជនច្រើនហើយ ហើយដើម្បីបង្ហាញអំពីគុណភាពនៃការសិក្សាអប់រំរបស់កម្ពុជា សាកលវិទ្យាល័យឯកជនទាំងនោះអាចទទួលសិស្សអាហារូបករណ៍បរទេសមកសិក្សានៅកម្ពុជាបាន។

ជាមួយនេះលោកនាយករដ្ឋមន្ត្រីប៊ូសន បុប្ផាវ៉ាន់ ក៏បានសំដែងនូវការអរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចតេជោហ៊ុន សែន ដែលបានផ្តល់កិត្តិយសដល់ប្រទេសឡាវបានអញ្ជើញមកចូលរួមក្នុងពិធីបើកការប្រកួតកីឡាស៊ីហ្គេមលើកទី២៥នេះ។ ទន្ទឹមនឹងនេះ សម្តេចតេជោហ៊ុនសែនក៏បានអបអរសាទរ ចំពោះការខិតខំប្រឹងប្រែងក្នុងការរៀបចំការប្រកួតកីឡាស៊ីហ្គេមនេះដែរ។ សម្តេចតេជោបានមានប្រសាសន៍ថានេះជាលើកទី១ ក្នុងឋានៈសម្តេចជានាយករដ្ឋមន្ត្រីបានមកចូលរួមក្នុងការបើកពិធីប្រកួតកីឡាស៊ីហ្គេមលើកទី២៥។

ដោយឡែកសម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានជួបពិភាក្សាការងារជាមួយលោកនាយករដ្ឋ-មន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាមផងដែរ ដែលក្នុងនោះ ភាគីទាំងពីរបានផ្តោតការយកចិត្តទុកដាក់លើការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-វៀតណាម ក្នុងការអូសទាញវិនិយោគទុនមកវិនិយោគនៅកម្ពុជាលើវិស័យកសិកម្ម ថាមពល និងរ៉ែ។

2. ចិននិងអាមេរិកផ្លាស់ប្តូរសង្គ្រាមពាក្យសម្តីជុំវិញបញ្ហាបំពុលបរិស្ថាន

គណៈប្រតិភូចិនដែលចូលរួមការប្រជុំកំពូលស្តីអំពីការប្រែប្រួលអាកាសធាតុនៅក្នុងក្រុង Copenhagen ប្រទេសដាណឺម៉ាក បានធ្វើការបញ្ជាក់ឡើងវិញចំពោះការប្តេជ្ញាចិត្តរបស់ចិនក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាបន្លាស់ប្តូរអាកាសធាតុ ហើយបានរិះគន់ដល់សហរដ្ឋអាមេរិកថា មិនបានធ្វើទៅតាមការប្តេជ្ញាចិត្តរបស់ខ្លួន។

សង្គ្រាមពាក្យសម្តីរវាងរដ្ឋាភិបាលក្រុងវ៉ាស៊ីងតោន និងរដ្ឋាភិបាលក្រុងប៉េកាំងបានកើតឡើងនៅថ្ងៃទី៤នៃអង្គសន្និសីទនេះ ដោយប្រតិភូកំពូលរបស់ចិននិយាយបន្ទោសដល់ប្រទេសជាច្រើនដូចជាសហរដ្ឋអាមេរិកថា បានបណ្តាលឲ្យមានបញ្ហាដែលគេគ្រប់គ្នាត្រូវមកចូលរួមប្រជុំ ដើម្បីដោះស្រាយរួមគ្នា។ ប្រធាននាយកដ្ឋានសន្ធិសញ្ញានិងច្បាប់នៃប្រទេសចិនដែលស្ថិតនៅក្រោមក្រសួងការបរទេសចិន បានទិតៀនដល់អាមេរិកថា បានបរាជ័យនៅក្នុងការធ្វើទៅតាមការប្តេជ្ញាចិត្តរបស់ខ្លួនដែលមានអាយុកាល១៧ឆ្នាំ ដើម្បីផ្តល់ជំនួយហិរញ្ញវត្ថុដល់បណ្តាប្រទេសកំពុងអភិវឌ្ឍ និងដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នបំពុលបរិស្ថានរបស់ខ្លួន។

ប៉ុន្តែប្រធានអ្នកចរចារបស់អាមេរិកវិញ បានឆ្លើយតបដោយចង្អុលបង្ហាញថា ប្រទេសចិនគឺជាប្រទេស ដែលបញ្ចេញឧស្ម័នបំពុលបរិស្ថានច្រើនជាងគេបំផុតនៅក្នុងពិភពលោក ហើយបាននិយាយថា គេមិនអាចសម្រេចបាននូវកិច្ចព្រមព្រៀងនៅក្រុង Copenhagen បានឡើយ ប្រសិនបើគ្មានការប្តេជ្ញាចិត្តពីលោកនាយករដ្ឋមន្ត្រីចិន Wen Jiabao ក្នុងការកាត់បន្ថយឧស្ម័នបំពុលបរិស្ថានទេនោះ៕

三、请用柬文写作文（共 50 分）

作文题：《对我影响最深的柬埔寨人物》

要求：1. 先翻译题目后撰文；2. 字数要求 600–800 词